ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ៩២...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត តឺតឺ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើ មាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

## សម្រេច

**មាត្រា១..**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត តីតី** ដែលមានទីតាំងស្ថិតនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**មាត្រា២..**

**តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត តីតី** មានទំហំ ៥៣ ហិកតា ៣៩ អា និង ៥៥ សង្ទីអា (ហាសិបបីហិកតា សាបសិបប្រាំបួនអា និងហាសិបប្រាំសង្ទីអា) ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ចជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

**មាត្រា៣..**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត តីតី** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន។

**មាត្រា៤..**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត តីតី** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងក្រុមហ៊ុន ប៉ោយប៉ែត ភីភី អេសអ៊ីហ្សិត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តាសោភា**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធាន ក.អ.ក
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ: ១០២៨ ដនស/អសក

ថ្ងៃ ពុធ ១កើត ខែពិសាខ ឆ្នាំរកា ព.ស.២៥៦០

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មេសា គ.ស. ២០១៧

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**និងជាអគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា**

**<u>កម្មវត្ថុ</u>:** ស្តីពីការផ្តល់ទិដ្ឋាការលើតារាងនិយាមកាចំណុចព្រំដី និងប្លង់បង្ហាញទីតាំងក្បាលដី តំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី ស្ថិតនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

**<u>យោង</u>:** - លិខិតលេខ ៣៧០៧/១៥ គ.ស.ព ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- លិខិតលេខ ១៣៧៧/១៦ ដនសស.បជ សដភ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៦ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** ជ្រាបថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឯកភាពផ្តល់ទិដ្ឋាការលើតារាងនិយាមកាចំណុចព្រំដី និងប្លង់បង្ហាញទីតាំងក្បាលដី សម្រាប់បង្កើតតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភី ដែលមានទីតាំងស្ថិតនៅ ភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ របស់ក្រុមហ៊ុន ប៉ោយប៉ែត ភីភី អេសអ៊ីហ្សិត (POI PET PP SEZ Co.,LTD) ដែលមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ បានចាត់មន្ត្រីជំនាញចុះធ្វើការកំណត់ព្រំ និងវាស់វែងតាមនីតិវិធីរួចហើយ ដែលមានទំហំដីសរុបចំនួន ៥៣ ហិកតា ៣៩ អា ៥៥សង់ទីអា (ហាសិបបីហិកតា សាមសិបប្រាំបួនអា និងហាសិបប្រាំសង់ទីអា) ដោយកសាងបានជាប្លង់បង្ហាញទីតាំងក្បាលដី និងតារាងនិយាមកាចំណុចព្រំដីដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ** ទទួលយកទិន្នន័យនេះ សម្រាប់ចាត់ចែងបន្តតាមនីតិវិធីតាមការគួរ។

សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

<u>ចម្លងជូន</u>
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រដ្ឋបាលខេត្តបន្ទាយមានជ័យ
  "ដើម្បីជូនជ្រាប"
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ
- ក្រុមហ៊ុន ប៉ោយប៉ែត ភីភី អេសអ៊ីហ្សិត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

ប្លង់បន្ទាត់ព្រំដីតាំង ដែលគ្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេស ទេិយមេិត តីគី របស់ក្រុមហ៊ុន ទេិយមេិត តីគីអេសអុីហ្សិត

ស្ថិតនៅភូមិសាស្ត្រ ភូមិផ្សារកណ្ដាល សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ




| ការពិពណ៌នាការបញ្ជូនប្រព័ន្ធភាគ | | |
|---|---|---|
| ប្រភព : អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ | | |
| Projection UTM, Zone48N, Datum WGS84 | | |
| Point_ID | NORTHING (m) | EASTING (m) |
| 105002 | 1508365.467 | 241353.163 |
| BM02 | 1508359.028 | 241358.383 |

| ការពិពណ៌នាការចំណុចព្រំដី | | |
|---|---|---|
| Projection UTM, Zone48N, Datum WGS84 | | |
| Point_ID | Easting (m) | Northing (m) |
| 1 | 241701.322 | 1509211.594 |
| 2 | 241800.103 | 1509401.538 |
| 3 | 241891.008 | 1509576.339 |
| 4 | 241923.696 | 1509626.768 |
| 5 | 241828.189 | 1509647.658 |
| 6 | 241492.309 | 1509710.977 |
| 7 | 241565.610 | 1509844.825 |
| 8 | 241749.749 | 1510188.328 |
| 9 | 241692.633 | 1510216.748 |
| 10 | 241698.050 | 1510247.029 |
| 11 | 241640.444 | 1510251.086 |
| 12 | 241450.874 | 1510266.277 |
| 13 | 241274.968 | 1510277.151 |
| 14 | 241227.871 | 1510143.837 |
| 15 | 241069.607 | 1510215.358 |
| 16 | 241082.177 | 1510289.048 |
| 17 | 240998.566 | 1510293.317 |
| 18 | 240895.388 | 1510301.316 |
| 19 | 240804.836 | 1510310.178 |
| 20 | 240657.455 | 1510321.950 |
| 21 | 240633.163 | 1510217.443 |
| 22 | 240726.166 | 1510188.398 |
| 23 | 240793.461 | 1510189.036 |
| 24 | 240843.778 | 1510164.618 |
| 25 | 240840.520 | 1510107.050 |
| 26 | 241048.659 | 1510081.079 |
| 27 | 241041.918 | 1510042.619 |
| 28 | 241016.433 | 1509771.097 |
| 29 | 241277.587 | 1509717.600 |
| 30 | 241179.055 | 1509454.793 |
| 31 | 241353.546 | 1509428.245 |
| 32 | 241346.836 | 1509526.628 |
| 33 | 241425.629 | 1509505.031 |
| 34 | 241754.111 | 1509414.249 |
| 35 | 241658.686 | 1509231.811 |

**សញ្ញាសំគាល់**

- ● ចំណុចព្រំដី
- ព្រំដី
- ផ្លូវ ទទឹង ៥០ ម៉ែត្រ
- ផ្លូវ ទទឹង ១២ ម៉ែត្រ
- ក្បាលដីស្នើសុំវាស់វែង

ផ្ទៃក្រឡាដីសរុប: ៥៣,៣៥៥៥ ហិកតា

រៀបចំដោយ: មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ

ឧបករណ៍វាស់វែង: Leica Viva Uno